# ការសំភាសន៍របស់អ៊ុំស្រី អន វ៉ន

ក៖ អ្នកដែរសំភាសន៍គេមាន ជាងស៊ីអ៊ារ ខ៖ អ្នកដែរអោយគេសំភាសន៍មាន អន វ៉ន

## <u>ការសង្ខេបប្រវត្តិរបស់អ៊ុំស្រី អន វ៉ន</u>

អ៊ុំស្រី អន វ៉ន មានអាយុ 53ឆ្នាំ នៅក្នុងឆ្នាំ2018អ៊ុំស្រី អន វ៉ន មានភេទស្រី ។ អ៊ុំស្រី អន វ៉ន មានទីលំនៅបច្ចុប្បន្ននៅភូមិស្វាយរលំ ឃុំស្វាយរលំ ភូមិមួយ ស្រុកស្អាង ខេត្តកណ្ដាល។

ក៖ ចឹងជាដំបូងខ្ញុំសូមអរគុណច្រើនអ៊ុំដែរបានអោយខ្ញុំសំភាសន៍ពីប្រវត្តិរបស់អ៊ុំ ហើយការសំភាសន៍
នេះត្រូវបានរៀបចំឡើងដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចដែរមានឈ្មោះថាBYU ហើយដោយសារតែសកលវិទ្យាល័យមានគោលបំណងចង់រក្សាពីប្រវត្តិប្រជាជនខ្មែរដើម្បីទុកអោយកូនចៅ ជំនាន់ក្រោយៗពួកគាត់បានស្គាល់ពីប្រវត្តិរបស់ឪពុកម្ដាយ នឹងប្រវត្តិរបស់ដូចតា ចឹងនៅពេលដែរខ្ញុំបាន
សំភាសន៍អ៊ុំហើយខ្ញុំនឹងដាក់ការសំភាសន៍មួយនេះទៅក្នុងវេបសាយរបស់សាលាដែរមានឈ្មោះថា www.cambodianoralhistories.byu.edu ចឹងហាសអ៊ុំ
ចឹងតើអ៊ុំយល់ព្រមដើម្បីអោយខ្ញុំដាក់ការសំភាសន៍
មួយនេះទៅក្នុងវេបសាយរបស់សាលាដែរទេអ៊ុំ?

ខ៖ ថាម៉េច?

ក៖
ចង់និយាយថាអ៊ុំយល់ព្រមដើម្បីអោយខ្ញុំដាក់ការសំភាសន៍មួយនឹងទៅក្នុងវេបសាយរបស់សាលាដែរ ទេអ៊ុំ?

ខ៖ អត់យល់ទេខ្ញុំនឹង

ក៖
ចង់និយាយថាខ្ញុំបានសំភាសន៍អ៊ុំចឹងខ្ញុំនឹងយកការសំភាសន៍មួយនឹងទៅដាក់ក្នុងវេបសាយ ដើម្បីទុក ដាក់អោយកូនចៅរបស់អ៊ុំបានស្ដាប់ពីប្រវត្តិរបស់អ៊ុំចឹងហាស?

ខ៖ ចា៎ៗៗ!!

ក៖ ចឹងសំរាប់ខ្ញុំជាអ្នកដែរសំភាសន៍អ៊ុំខ្ញុំមានឈ្មោះថា ជាង ស៊ីអារ ហើយថ្ងៃខែដែរខ្ញុំសំភាសន៍អ៊ុំមួយនេះត្រូវបាន ធ្វើឡើងនៅថ្ងៃទី22 ខែ2 ឆ្នាំ2018 សំភាសន៍នៅភូមិស្វាយរលំ ឃុំស្វាយរលំ

ខ៖ ភូមិ1

ក៖ ភូមិ1ហោស?

ខ៖ ចា៎!នឹង

ក៖ ភូមិ1 ឃុំស្វាយរលំ

ខ៖ ភូមិស្វាយរលំ ឃុំស្វាយរលំ ភូមិ1

ក៖ ភូមិ1ណោះអ៊ុំណោះ ស្រុកស្អាង ខេត្តកណ្តាល ចឹងសំរាប់ឈ្មោះពេញរបស់អ៊ុំនឹងមានឈ្មោះអីគេ ដែរអ៊ុំ?

ខ៖ ចាស៎!

ក៖ ឈ្មោះពេញរបស់អ៊ុំហាស?

ខ៖ ឈ្មោះខ្ញុំមានឈ្មោះតែមួយនឹង អន សារ៉ន

ក៖ ឈ្មោះអន សារ៉ន មានឈ្មោះហៅក្រៅទេអ៊ុំ?

ខ៖ អត់មាន

ក៖ ចុះកាលពីក្មេងមាននរណាគេហៅឈ្មោះអីផ្សេងទេអ៊ុំ?

ខ៖ អត់ទេ

ក៖ ចុះសព្វថ្ងៃនឹងអ៊ុំអាយុប៉ុន្មានដែរអ៊ុំ?

ខ៖ អាយុ53ឆ្នាំ

ក៖ អាយុ53ឆ្នាំ ចុះអ៊ុំមានចងចាំថ្ងៃដែរអ៊ុំកើតទេអ៊ុំ ថាអ៊ុំកើតនៅថ្ងៃខែឆ្នាំណា?

ខ៖  ខ្ញុំកើតនៅក្នុងឆ្នាំ1961រឺមួយក៏ឆ្នាំ1960ទេនេះ
ភ្លេចហើយឥឡូវហើយនឹងបើមិនឆ្នាំ1961រឺឆ្នាំ1960

ក៖  អ៊ុំមិញអាយុប៉ុន្មានដែរអ៊ុំ?

ខ៖  អាយុ53ឆ្នាំ

ក៖  អាយុ53ឆ្នាំចឹងអ៊ុំកើតឆ្នាំ1965អ៊ុំប្រទ្បំហើយអ៊ុំ?

ខ៖  ឆ្នាំ1965ហោស?

ក៖  បាទអ៊ុំបាទ?

ខ៖  អត់មានទេបើខ្ញុំបើមិនឆ្នាំ1964រឺមួយឆ្នាំ1963 រឺឆ្នាំ1961?

ក៖  អ៊ុំអត់ច្បាស់ទេហោសអ៊ុំប៉ុន្តែអ៊ុំដឹងតែអ៊ុំអាយុ53ឆ្នាំ?

ខ៖  ចា៎!នឹងហើយ

ក៖  ចឹងនៅឆ្នាំ1965?

ខ៖  ចឹងមានតែអាយុ54ឆ្នាំនឹង

ក៖  ចុះដូចជាឆ្នាំខ្មែរអ៊ុំឆ្នាំអីដែរអ៊ុំដូចជាឆ្នាំជូត ឆ្លូវ ខាល
ថោះហាសអ៊ុំភ្លេចថាអ៊ុំកើតឆ្នាំអីហើយណាអ៊ុំ?

ខ៖  ខ្ញុំឆ្នាំម៉្សាញ់

ក៖  អ៊ុំឆ្នាំម៉្សាញ់ ចុះអ៊ុំកើតនៅភូមិកំណើតរបស់អ៊ុំនឹងអ៊ុំកើតនៅណាដែរ?

ខ៖  ខ្ញុំហោសខ្ញុំភូមិកំណើតកើតនឹងនៅភូមិស្វាយរលំនឹងហើយ
មកយាយប៉ារបស់ខ្ញុំនឹងនៅកណ្តុរទូកនឹម
កុងខាងម៉ែក្មេកខ្ញុំហាសម៉ែក្មេកប៉ារបស់ខ្ញុំនឹងហាស

ក៖  បាទអ៊ុំ?

ខ៖  ប៉ាក្មេកម៉ែរបស់ខ្ញុំនៅព្រែកស្លា

ក៖  ប៉ុន្តែអ៊ុំកើតនឹងអ៊ុំកើតនៅនឹង?

ខ៖ ខ្ញុំកើតនៅស្វាយរលំ តែដល់ពេលដែរការហើយនឹងកាលពីជំនាន់លុនណុលណុង

ក៖ បាទអ៊ុំបាទ?

ខ៖ កុងរបស់ខ្ញុំនឹងយកទៅព្រែកស្លា

ក៖ ចុះអ៊ុំមានបងប្អូនចំនួនប៉ុន្មាននាក់ដែរអ៊ុំ?

ខ៖ បងប្អូនរបស់ខ្ញុំនឹងទាំងអស់មាន5នាក់

ក៖ អ៊ុំជាកូនទីប៉ុន្មានដែរ?

ខ៖ ខ្ញុំជាកូនទី3នឹង

ក៖ ចុះអ៊ុំមានស្រីប៉ុន្មាននាក់ ហើយប្រុសប៉ុន្មាននាក់?

ខ៖ មានស្រី2នាក់

ក៖ មានស្រី2នាក់ ប្រុស3នាក់?

ខ៖ នឹងហើយប្រុសនាក់?

ខ៖ នឹងហើយប្រុស3នាក់

ក៖ អ៊ូ!ចំអ៊ុំអាចប្រាប់ឈ្មោះបងប្អូនរបស់អ៊ុំបានទេថាពួកគាត់មានឈ្មោះអីគេដែរចឹងហាស?

ខ៖ កូនរបស់ខ្ញុំហោស?

ក៖ អត់ទេបងប្អូនរបស់អ៊ុំហាស?

ខ៖ បងរបស់ខ្ញុំហោសបងណាន អន ណាន

ក៖ ចុះបងទី2វិញអ៊ុំ?

ខ៖ បងទី2នឹងអន គាល

ក៖ ទី3នឹងអ៊ុំ?

ខ៖ ទី3នឹងអន រ៉ន

ក៖ ចុះទី4វិញអ៊ុំ

ខ៖  ទី4នឹងអន សុខរុង

ក៖  ចុះកូនពៅគេអ៊ុំ?

ខ៖ ទី5នឹងឈ្មោះអន រំ

ក៖  បាទអន សុខរុង នឹង អន រំ?

ខ៖  អន សុខរុង នឹង អន រំ

ក៖ 
ចុះអ៊ុំមានចងចាំអនុស្សាវរីយ៍អីកាលពីអ៊ុំនៅក្មេងតើធ្លាប់បានលេងអីគេជាមួយពួកគាត់ដូច ជា នៅប៉ុននេះអីថាដូចជាលេងឡឹកបាយឡហាស?

ខ៖  អ៊ូ!កាលណុងប៉ារបស់ខ្ញុំនឹងគាត់ជាដង្វៅបឹងមិនសូវបានដើរលេង មិនសូវជាលេងជាមួយគេទេ ពីព្រោះអីពីដើមភូមិដល់ចុងភូមិខ្ញុំទៅតែមើលគេជល់មាន់

ក៖  អ៊ូ!មើលគេជល់មាន់ហោស?

ខ៖  នរណាគេបាញ់សត្វអីចឹងហាសធម្មតាទេកូនអ្នកមាន់

ក៖  អ៊ូ!បាទអ៊ុំ?

ខ៖ 
បាត់ខ្ញុំចឹងគាត់ដើររកខ្ញុំចង់ស្លាប់ខ្ញុំពួនតែនៅក្រោមផ្កាសេមាន់នឹងគ្រង់គោធំហាសផ្ទះរបស់ ខ្ញុំពីរបាន ស្មើរនឹងគ្រង់គោនឹងមួយហាស

ក៖  បាទអ៊ុំបាទ?

ខ៖  ហើយខ្ញុំនៅកន្លែងអីកន្លែងអាគោស៊ីនៅក្នុងទ្រុងនឹង កូនប៉ារបស់ខ្ញុំនៅតែក្នុងទ្រុងនឹងទេ ពួនតែក្នុង ទ្រុងនឹងបើពួនក្នុងជង្រុកស្រូវវិញផ្ទះប៉ុណ្ណឹងហាស ហើយផ្ទះបាយក៏ប៉ុណ្ណឹងដែរ

ក៖  កាលផ្ទះពីមុនហោសអ៊ុំ?

ខ៖  ចា៎!ពីដើមហាស

ក៖  បាទអ៊ុំបាទ?

ខ៖ កាលពីដើមហើយកម្មករម៉ែរបស់ខ្ញុំនឹងមានគ្នា27នាក់

ក៖ អូ៎!ច្រើនហាសណាអ៊ុំ?

ខ៖ ចា៎!សុទ្ធតែកម្មករនឹង

ក៖ គាត់ធ្វើអីគេដែរកាលពីដើមហាសអ៊ុំ?

ខ៖ ប៉ារបស់ខ្ញុំនឹងដង្ហៅបឹងហើយនឹងធ្វើស្រូវធ្វើអីចឹងហាសធ្វើស្រូវហាស

ក៖ ប៉ុន្តែពេលណុងអ៊ុំនៅណាដែរអ៊ុំ?

ខ៖ កាលណុងនៅកណ្តុរទូកនឹម

ក៖ កណ្តុរទូកនឹមនឹងនៅ?

ខ៖ នៅស្រុកស្រែ

ក៖ ប៉ុន្តែនៅក្នុងខេត្តនឹងដែរហោសអ៊ុំ?

ខ៖ អត់ទេនៅណោះ

ក៖ នៅខាងកំពង់ស្ពឺហីអ៊ុំ?

ខ៖
នៅខាងណុងហាសហើយខ្ញុំមានគោច្រើនហាសផ្ទះរបស់ខ្ញុំហើយធំៗដល់ពេលដែរដល់ជំនាន់
ឆ្នាំ1975នឹងបែកបងរបស់ខ្ញុំមួយនៅឆ្នាំ1975នឹងបែកបងរបស់ខ្ញុំមួយនឹងទៅធ្វើជាទាហ៊ាន
ទៅជំនាន់ណុង ឆ្នាំ1975នឹងគេចោទប៉ារបស់ខ្ញុំដង្ហៅបឹងហាស
គេចោទប៉ារបស់ខ្ញុំថាស័ក5ហាសគេសំលាប់ប៉ារបស់ខ្ញុំនឹង ចូលជិតឆ្នាំ1976

ក៖ អូ៎!ចឹងបាទ?

ខ៖
គេសំលាប់ប៉ារបស់ខ្ញុំហាសម៉ែរបស់ខ្ញុំគាត់ដួលបាក់ដៃគាត់ដេកតាំងឆ្នាំ1979នឹងដេកទាល់
តែបែក

ក៖ បាទអ៊ុំ?

ខ៖ ហើយចំណែកខ្ញុំនឹងហើយបងរបស់ខ្ញុំឈ្មោះអន គាលនឹងហាស

ក៖ បាទអ៊ុំបាទ?

ខ៖ ហើយនឹងប្អូនរបស់ខ្ញុំមួយឈ្មោះអន
រំនឹងនៅជាមួយខ្ញុំកំសត់ណាស់ប្អូនរបស់ខ្ញុំនឹងធំជាងមីល្អិតនឹង
បន្តិចកំសត់ណាស់នៅតែជាមួយខ្ញុំទេដល់ពេលដែរជិតបែកអាពតវេទនាប្អូនរបស់ខ្ញុំអាក្រោយនឹង ប៉ុន្តែស្លាប់អស់ហើយធ្វើជាទាហ៊ាន កាលពីជំនាន់ឆ្នាំ1985ហាស

ក៖ បាទអ៊ុំបាទ?

ខ៖
នៅឆ្នាំ1985នឹងធ្វើជាទាហ៊ានអាបងទៅយុវជនទៅកាលពីជំនាន់ឆ្នាំ1977នឹងខ្ញុំធ្វើជានារីឆ្នាំ1977នឹង ខ្ញុំដើរចោលប្អូនគេមិនអើយយកប្អូនទៅតាមទេ

ក៖ អូ៎!បាទអ៊ុំ ចុះពេលណុងអ៊ុំអាយុប៉ុន្មានដែរអ៊ុំ?

ខ៖ កាលណុងខ្ញុំអាយុក្រៃលដែរហើយនឹងប៉ុន្តែគ្រាន់តែខ្ញុំកាម៉ាប់មាឌវាធំហាស
ខ្ញុំមានមាឌធំហាស

ក៖ អូ៎!បាទអ៊ុំបាទ?

ខ៖ ពេលណុងបើមិនអាយុ15-16ឆ្នាំកាលណុង

ក៖ អ៊ុំដូចជាអាយុ14ឆ្នាំអ៊ុំ ដោយសារតែអ៊ុំកើតនៅឆ្នាំ1963-1964ហោស?

ខ៖ នឹងហើយប៉ុន្តែខ្ញុំធំហាសណាស់

ក៖ អ៊ុំមាឌធំហោស?

ខ៖ នឹងហើយមាឌធំណាស់និយាយរួចខ្ញុំស្លៀកតែខោកាពិលទេ
កាលនៅនារី1977ក៏ដោយខ្ញុំស្លៀកតែ ខោកាពិលទេ

ក៖ បាទអ៊ុំបាទ?

ខ៖
ចាំ!ខ្ញុំស្លៀកតែខោកាពិលទេហើយនារី1977នឹងវាសនាខ្ញុំទេអានឹងហោសខ្ញុំអត់នឿយទេ

គេអោយធ្វើ មើលកុមារធ្វើអាលើកភ្លើនោះ
ដូចថាម្នាក់មួយម៉ែត្រណាហើយមុននឹងឈប់ពីព្រោះខ្ញុំកំលាំងចឹងខ្ញុំដឹងតែ
ហើយមុនគេបង្អស់នឹងហើយខ្ញុំនៅលើចុងស្វាយហោសណុងកាលពីជំនាន់ណុងហាស

ក៖ អូ៎!អ៊ុំឡើងចេះស្វាយញ៉ាំហោស?

ខ៖ អត់ទេខ្ញុំឡើងលេងនឹងហាសប៉ុន្តែប្អូនហើយនឹងបងរបស់ខ្ញុំនឹងកំសត់

ក៖ អូ៎!បាទអ៊ុំ?

ខ៖ ប្អូនរបស់ខ្ញុំនឹងកំសត់ជាងគេដល់ពេលណុងនិយាយទៅប្អូនរបស់ខ្ញុំនឹងកំសត់ជាងគេ
ដល់ហើយវាទៅធ្វើជាទាហ៊ានឆ្នាំ1985មកពិការជើងទៀត

ក៖ អូ៎!គេបាញ់ត្រូវមែនអ៊ុំ?

ខ៖ ចា៎!មីនជំនាន់ណុងមីនច្រើនណាស់

ក៖ អូ៎!ជាន់មីនហោស?

ខ៖
នឹងហើយមីនច្រើនណាស់កាលពីជំនាន់ណុងមីននឹងក៏ដូចថាត្រូវរបស់គេហាសគ្នានណា
ទេ គ្នាឯងធ្វើបាបគ្នាឯងនឹង ច្រណែនហាសដូចថាយើងឡើងបុណ្យស័កចឹងទៅណាស់
ថាច្រណែនចឹងហាសបានប្អូនរបស់ខ្ញុំវាចឹង កាលជំនាន់ណុងវាដល់អាយុ33ឆ្នាំនឹង ឆ្នាំច
ស្លាប់នៅអាយុ33 ឆ្នាំវាស្លាប់នឹងនៅឆ្នាំកៅជាងហើយនេះកាលណុង

ក៖ បាទអ៊ុំបាទចឹង?

ខ៖
កាលណុងពួកយួនវាចុះហាសពួកយួននឹងវាចុះបុកហាសវាវាយសន្ធចនៅទន្លេហាសវាថា
វាមិន អាចសុំទាន់គេទេវារកស៊ីដោយខ្លួនវាឆ្នាំកៅជាង

ក៖ ចុះពេលណុងអ៊ុំនៅណាដែរអ៊ុំកាលពីជំនាន់ពលពតហាស?

ខ៖ នៅជំនាន់ពលពតខ្ញុំនៅព្រែកស្លា

ក៖ នៅព្រែកស្លាហោស?

ខ៖ ចា៎!នៅព្រៃកស្លា

ក៖ ប៉ុន្តែអ៊ុំនៅជាមួយគ្រួសាររបស់អ៊ុំរឺមួយក៏មិននៅជាមួយគ្រួសារទេ?

ខ៖ ទេខ្ញុំមិនទាន់មានប្តីផងនឹង

ក៖ អូ៎!អ៊ុំមិនទាន់មានទេណា
ប៉ុន្តែអ៊ុំនៅជាមួយគ្រួសាររបស់អ៊ុំតែម្តងនៅជាមួយគ្រួសាររបស់អ៊ុំតែម្តងរឺយ៉ាងម៉េចដែរ?

ខ៖ និយាយទៅខ្ញុំកំសត់តែម្តងនឹងប៉ាររបស់ខ្ញុំគេយកទៅវៃចោល
បងទៅធ្វើជាទាហ៊ានបាត់ម៉ែរបស់ខ្ញុំនឹង
គាត់ដេកនៅឆ្នាំ1979យើងនេះហើយខ្ញុំនៅព្រៃកស្លាយើងនេះពីរនាក់ប្អូននឹងប៉ុណ្ណឹងហាស
ធំជាងនឹងបន្តិច

ក៖ ចឹងមានន័យថាបងប្អូនរបស់អ៊ុំឥឡូវនឹងមានសល់ប៉ុន្មាននាក់ដែរអ៊ុំ?

ខ៖ ឥឡូវនឹងនៅសល់តែ3នាក់ទេ

ក៖ នៅសល់តែ3នាក់ទេណាអ៊ុំ ប្អូន៣ស្លាប់?

ខ៖ មានប្អូនមួយទៀតនឹងស្លាប់

ក៖ ចឹងប្អូនរបស់អ៊ុំនឹងស្លាប់ទាំងពីរ?

ខ៖ ស្លាប់

ក៖ ចឹងបងៗរបស់អ៊ុំនៅទេណាអ៊ុំ?

ខ៖ បងស្លាប់មួយបាត់មួយអាមួយនេះម៉ែខ្ញុំរើសបានមួយនឹង

ក៖ អូ៎!បាទអ៊ុំបាទ?

ខ៖ អាមួយនឹងឈ្មោះមាំបុរី

ក៖ បាទចឹងអ៊ុំ?

ខ៖
នឹងអាប្អូនពៅខ្ញុំមួយឥឡូវនឹងនៅសល់តែ3នាក់ទេពីព្រោះពីមុនមកនៅសល់តែ2នាក់ទេណាស់ ឥឡូវនឹងនៅសល់3នាក់អាកូនក្រោយមួយនឹងទៀត

ក៖ ចុះអ៊ុំគិតថាអ៊ុំចូលចិត្តលេងអីជាមួយបងប្អូនរបស់អ៊ុំកាលពីនៅក្មេងៗហោស?

ខ៖ ខ្ញុំចូលចិត្តមើលខាងគេជល់មាន់

ក៖ អូ៎!ខាងជល់មាន់ហោសអ៊ុំ?

ខ៖ ចា៎!ផ្ទះរបស់ខ្ញុំនឹងមានមាន់ជល់
មាន់ជល់នឹងវាមិនមានកន្ទុយទេណាស់ជំនាន់ឆ្នាំ1975នឹង
មាន់នឹងអោយហេតុហោសគេចាក់វាត្រូវភ្នែកតែវាវៃគេស្លាប់ដែរណាស់ខ្ញុំចូលចិត្តមើលមាន់

ក៖ អ៊ុំចូលចិត្តមើលមាន់ដូចមនុស្សប្រុសដែរណអ៊ុំ?

ខ៖ ចូលចិត្តមើល

ក៖ ចុះបងប្អូនរបស់អ៊ុំឥឡូវនឹងគាត់នៅណាដែរអ៊ុំ?

ខ៖ នៅខាងក្រោមហោសនៅភូមិមួយដែរប៉ុន្តែនៅជិតរោងគុយទាវហោស

ក៖ ចុះពួកគាត់ធ្វើអីគេដែរអ៊ុំឥឡូវនឹង?

ខ៖ គាត់រកស៊ីអីនឹងប្អូនខ្ញុំអាមួយនឹងរកស៊ីចាអាពៅនឹង

ក៖ អូ៎!ចឹងទេហោស?

ខ៖ នឹងហើយ

ក៖ ចុះម្ដាយរបស់អ៊ុំអាយុប៉ុន្មានដែរអ៊ុំ?

ខ ម្ដាយរបស់ខ្ញុំនឹងគាត់ឈ្មោះយៃម រុណ

ក៖ ចុះគាត់អាយុប៉ុន្មានដែរអ៊ុំចាំទេដល់ឥឡូវនឹងហាស?

ខ៖ អូ៎!ម៉ែរបស់ខ្ញុំនឹងអាយុ87ឆ្នាំហោស

ក៖ ប៉ុន្តែគាត់នៅរស់នឹងតើហីអ៊ុំ?

ខ៖ គាត់នៅតើម៉ែរបស់ខ្ញុំនឹង

ក៖ អ៊ូ!ល្អប៉ុន្តែគាត់នៅណាដែរអ៊ុំ?

ខ៖ ម៉ែរបស់ខ្ញុំនឹងនៅជាមួយប្អូនរបស់ខ្ញុំអាពៅនឹង

ក៖ អ៊ូ!ប៉ុន្តែគាត់កើតនៅណាអ៊ុំមានដឹងទេអ៊ុំ?

ខ៖ ចាស៎!!?

ក៖ ម្តាយរបស់អ៊ុំគាត់កើតនៅណាអ៊ុំមានដឹងទេ?

ខ៖ ខ្ញុំអត់ដឹងទេ

ក៖ ចុះឪពុករបស់អ៊ុំនឹងមានឈ្មោះអីគេដែរអ៊ុំ?

ខ៖ ប៉ារបស់ខ្ញុំហោសឈ្មោះអន

ក៖ ចុះប៉ុន្តែគាត់អាយុប៉ុន្មានអ៊ុំមានដឹងទេ?

ខ៖ គាត់ស្លាប់យូរដែរហើយនឹង

ក៖ ប៉ុន្តែគាត់បងប្អូនម្តាយរបស់ប៉ុន្មានឆ្នាំដែរ?

ខ៖ ប៉ារបស់ខ្ញុំអាយុ83ឆ្នាំ

ក៖ ចឹងបងគ្នា6ឆ្នាំណាអ៊ុំ?

ខ៖ ចា៎!បងគ្នា6ឆ្នាំគាត់អាយុ83ឆ្នាំហើយ

ក៖ អ៊ូ!បាទប៉ុន្តែឪពុករបស់អ៊ុំនឹងគាត់កើតនៅណាដែរអ៊ុំមានដឹងទេ?

ខ៖ ប៉ារបស់ខ្ញុំហោស?

ក៖ បាទស្រុកកំណើតរបស់គាត់នឹងនៅណាដែរអ៊ុំមានដឹងទេ?

ខ៖ កើតនៅព្រែកស្លាហោស

កៈ នៅព្រែកស្លា
ចុះឪពុករបស់អ៊ុំនឹងកាលពីគាត់នៅរស់នឹងគាត់ធ្វើអីគេសំរាប់ចិញ្ចឹមជីវិតដែរអ៊ុំ
លក្ខណៈចិញ្ចឹមគ្រួសារ នឹងចិញ្ចឹមជីវិតហាស?

ខៈ ប៉ារបស់ខ្ញុំដង្កៅបឹងនឹងហើយ

កៈ អូ៎!គាត់ជាដង្កៅបឹងតែម្តងហោសអ៊ុំ?

ខៈ ចា៎!គាត់ដង្កៅបឹងនេះ

កៈ ចុះគាត់ស្លូតរឺមួយក៏កាចដែរអ៊ុំ?

ខៈ ប៉ារបស់ខ្ញុំនឹងស្លូតណាស់

កៈ ចុះម្តាយរបស់អ៊ុំគាត់ធ្វើអីគេសំរាប់ចិញ្ចឹមជីវិតដែរអ៊ុំ?

ខៈ ម៉ែរបស់ខ្ញុំនឹងហោសមានអីកាលពីប៉ារបស់ខ្ញុំនៅរស់នឹងគាត់នៅតែផ្ទះនឹង

កៈ គាត់ជាស្ត្រីមេផ្ទះហោសអ៊ុំ?

ខៈ ចា៎!

កៈ ដោយសារតែប៉ារបស់អ៊ុំជាអ្នកមានហើយណាអ៊ុំ?

ខៈ ចា៎!នឹងហើយចឹង

កៈ ចុះម្តាយរបស់អ៊ុំគាត់ស្លូតរឺមួយក៏កាចដែរអ៊ុំ?

ខៈ ម៉ែរបស់ខ្ញុំនឹងមិនហ៊ានថាដែរទេគាត់រៀងគួរសមដែរនឹង

កៈ ចុះអ៊ុំមានចងចាំអនុស្សាវរីយ៍កាលពីអ៊ុំនៅជាមួយម្តាយឪពុករបស់អ៊ុំទេ
ធ្លាប់បានធ្វើអីជាមួយគ្នាខ្លះដែរចឹងហាស?

ខៈ និយាយរួមទៅប៉ារបស់ខ្ញុំនឹងស្រលាញ់ខ្ញុំណាស់គាត់មិនអោយខ្ញុំនឹងបំរើនរណាគេទេ
គាត់ស្រលាញ់ខ្ញុំហាស

កៈ អូ៎!បាទអ៊ុំ?

ខ៖
ហើយគាត់គ្រូបាយាយគាត់នឹងខ្លាំងណាស់នរណាប៉ះសក់ក្បាលខ្ញុំក៏មិនបានដែរគាត់កាន់ខ្ញុំហាស
ប៉ុន្តែដល់ពេលឥឡូវនឹងខ្ញុំចេះតែកាត់បន្ថយៗទៅមិនអោយគេប៉ះក្បាលខ្ញុំបានទេបើមិនធ្វើបាបខ្ញុំ
រឺធ្វើបាបគេហើយហើយដល់ពេលហើយឥឡូវនឹងគាត់មិនរវល់នឹងខ្ញុំទេគាត់ទៅរវល់នឹងបងរបស់ខ្ញុំហាស

ក៖ បាទអ៊ុំបាទ?

ខ៖ ហើយឥឡូវនឹងគាត់ចង់មកនៅជាមួយកូនខ្ញុំគ្រូរបស់គាត់នឹងហាស

ក៖ ម្តាយរបស់អ៊ុំហោស?

ខ៖ គ្រូប៉ារបស់ប៉ាខ្ញុំ ដល់ហើយប៉ារបស់ខ្ញុំនឹងគាត់ស្លូតគាត់ស្រលាញ់ខ្ញុំណាស់
ថាទៅណាចុះកាលណុង មានស្អីណាមានរទេះសំលី
នឹងមានកង់ឈើនឹងវាមិនទាន់ទំនើបដូចឥឡូវនឹងណាប៉ារបស់ខ្ញុំហាសបាយ
គេដាក់សង្រែកវែកចឹងហាស

ក៖ បាទអ៊ុំបាទ?

ខ៖ បាយដាក់សង្រែកវែក
សម្លចឹងដាក់សង្រែកវែកគាត់វែកបាយអោយជួយយួរសំលហើយគាត់វែកខ្ញុំ
ម្ខាងនឹងគាតស្រលាញ់ខ្ញុំហាសណាស់

ក៖ បាទអ៊ុំបាទចឹង?

ខ៖ កូនទាំងអស់នឹងស្រលាញ់ខ្ញុំជាងគេតែម្តងនឹង

ក៖ ចឹងគាត់ទៅណាក៏គាត់នាំអ៊ុំទៅដែរណអ៊ុំ?

ខ៖
នឹងហើយគាត់អ៊ារទៅដែរណាស់តែខ្ញុំតើនឹម៉ែខ្ញុំនឹងមីអូនដើបនៅតាមពិតខ្ញុំដឹងខ្លួនហើយប៉ុន្តែខ្ញុំគេច ហាស

ក៖ អ៊ុំមិនចង់ទៅណា?

ខ៖ អត់ចង់ទៅណាទេដល់ពេលហើយចឹងទៅបើកទ្វូសិន
ម៉ែរបស់ខ្ញុំនឹងគាត់នៅតុកតាក់ៗនៅបត់ភួយ
បត់មុងហាសចុះមនុស្សខ្ជចចេះតាមក្រោយខ្នងគាត់ចឹងទៅពួនកន្លែងទូមួយ
រួចពីមួយកន្លែងចឹងទៅពួន នៅកន្លែងជើងសសរមួយទៀតនៅលើផ្ទះហាស

ក៖ បាទអុំ?

ខ៖ ទំរាំចុះពីលើផ្ទះនឹងសឹងថាចង់មួយម៉ោងបានចេញរួចពីលើផ្ទះចុះផ្ទះធំហោស

ក៖ បាទចឹងអុំ?

ខ៖
ពួនលិចពួនកើតចុះគាត់ជូតលើផ្ទះនោះគាត់ថៃនៅលើផ្ទះហោសគាត់ថៃរូបសំណាក់ប៉ារបស់ខ្ញុំអីនោះ គេចចុះគេចឡើងនឹងចុះមកគ្រាន់តែឃើញប៉ារបស់ខ្ញុំដើរមកពីក្រោលគោវិញ
ខ្ញុំអាកៀនពាងនឹងចូលទៅ ក្នុងពាងនឹងផ្អុក

ក៖ រត់ពួនគាត់?

ខ៖
ចាំ!ពាងទឹកនឹងទឹកត្រឹមនឹងហាសទឹកជិតពេញពាងនឹងទឹកពាក់កណ្តាលពាងនឹងហើយក្រប់

ក៖ ក្រប់គំរបពាង់?

ខ៖
នឹងហើយក្រប់គំរបពាងនឹងហាប់ចង់ស្លាប់នឹងដល់ពេលហើយខ្ញុំចេះតែហើបបន្តិចៗនឹងអើយខ្យល់ ចូលនឹងហាស

ក៖ បាទម៉េចទៅ?

ខ៖
មីអូននៅណាអូមិនទាន់ងើបផងនឹងអើរទៅមើលមីអូនសិនដល់ពេលដែរគាត់ទៅមើលខ្ញុំចឹងទៅ

ក៖ អត់ឃើញហោសអុំ?

ខ៖ ថាម៉ែមីងអូនកូនទៅណាបាត់ហើយនឹងកូនចុះបាត់ហើយឯងរកមិនឃើញទេ ម៉ែថាខ្ញុំឃើញវាមិញនឹង តើមិញនឹងឃើញតែភួយហើយនឹងខ្នើយ វាដាក់តែភួយហើយនឹងខ្នើយដូចយើងដេកចឹងហាស

ក៖ អូ!បាទចឹងម្ដាយឪពុកខាងឪពុកនឹងអ៊ុំមានស្គាល់ឈ្មោះគាត់ដែរទេអ៊ុំ?

ខ៖ អត់ស្គាល់ទេនឹង

ក៖ ចុះយាយតាខាងម្ដាយវិញអ៊ុំមានស្គាល់ឈ្មោះគាត់ដែរទេ?

ខ៖ ខ្ញុំស្គាល់តែឈ្មោះតាខ្ញុំមួយនឹងតាយែមនឹង

ក៖ ចឹងយាយមិនស្គាល់ទេណាអ៊ុំ?

ខ៖ យាយមិនស្គាល់ទេ

ក៖ ចុះអ៊ុំមានដឹងថាតានៅខាងម្ដាយនឹងគាត់កើតនៅណាដែរអ៊ុំមានដឹងទេ?

ខ៖ តាគាត់កើតនៅខាងត្រើយស្លានឹងតាឯក

ក៖ ចុះអ៊ុំមកនៅខេត្តនឹងយូរនៅ មកនៅកន្លែងនឹងយូរនៅ?

ខ៖ នៅនឹងយូរហើយ

ក៖ នៅតាំងពីអ៊ុំកើតនៅនឹងតែម្ដងនឹងរឺយ៉ាងណាដែរអ៊ុំ?

ខ៖ អូ!កាលពីជំនាន់អាពតនឹងកុងអីខ្ញុំយកទៅត្រើយស្លាខ្ញុំនៅណុងដែរតើ ដល់ពេលដែរបែកពីអាពតនឹង មកនៅជំនាន់1987បានខ្ញុំមកវិញតើ

ក៖ អូ!បាទអ៊ុំចុះអ៊ុំមានបងប្អូនរឺមួយក៏កូនចៅណាមួយដែរតរស់នៅក្រៅប្រទេសទេអ៊ុំ?

ខ៖ មាននៅថៃមួយ

ក៖ គាត់ធ្វើអីគេដែរនៅថៃហោសអ៊ុំ?

ខ៖ កូនរបស់ខ្ញុំនឹងសាលានឹងដូចថាសាលាថាចេះសាលាគេបោកវាហាស

ក៖ អូ!បាទអ៊ុំចឹងហោស?

ខ៖ វានៅនេះវាខឹងប៉ាពេកហើយវាបាត់ទូរស័ព្ទនៅផ្ទះនឹងវាអកស្រីហាស នៅណុងធ្វើការរោងចក្រធ្វើជា ប្រធានតើនឹងដល់ពេលធ្វើមហារដើពរបស់គេទៀតហាស ដល់ពេលហើយទៅនៅជំណើរនឹងគេបោក យើងទេលាសាយើងនឹងចុះទេវតានឹងវាមានភ្នែក រួចទៅចូលចំកន្លែងនឹងមានគេជួយចឹងទៅវាចេះតែបាន លុយផ្ញើរមកខ្ញុំ ហើយខ្ញុំសួរថាវានៅណាវាថាម៉ែខ្ញុំនៅថៃហោស វាមិននិយាយថាវេចាញ់បោកគេទេ

ក៖ អូ៎!បាទអ៊ឺបាទ?

ខ៖ ដល់ពេលដែរចុងក្រោយនឹងវាថាម៉ែអើយវាតេមកហាសខ្ញុំអស់អីពីខ្លួនហើយគេបោកខ្ញុំ

ក៖ គេបោកនៅថៃនឹងរឺក៏គេបោកនៅខ្មែរនឹងអ៊ឺ?

ខ៖ គេបោកនៅថៃ

ក៖ ចាញ់បោកថៅកែហោសអ៊ឺ?

ខ៖ ចាញ់បោកខ្មែរគ្នាឯងនឹង

ក៖ អូ៎!លក្ខណះថាមេខ្យល់នឹងហោសអ៊ឺ?

ខ៖ នឹងហើយវាថាម៉ែអើយគេលួចហាសនៅជាមួយគ្នានឹងយើងទុកចិត្តគ្នា

ក៖ យើងដើរទៅធ្វើការយើងទុកចិត្តគ្នាចឹងហោសអ៊ឺ?

ខ៖
យើងទុកចិត្តគ្នាហាសម៉ែអើយគេលួចអស់រលីងហើយម៉ែអើយខ្ញុំសឹងតែរកលុយស៊ីបាយមិនដឹងបាន ផងនឹងតែបានកូនប្រសារនឹងហាស

ក៖ បាទអ៊ឺ?

ខ៖
អាកូនប្រសារនឹងវាចេះតែទៅកន្លែងវានឹងហើយដល់ហើយវាអោយម៉ែវាទៅកន្លែងទៅសួរទៅការនៅ កន្លែងណុងតើនឹងហើយគេបើកទូរស័ព្ទអោយយើងមើលចឹងគេចងដៃការចឹងម៉ែក្មេកវានឹងថាអ្នកដន្លង មើលអោយហើយអ្នកដន្លងកូនហោស

ក៖ បាទអ៊ឺបាទ?

ខ៖  នឹងហើយចឹង

ក៖  ចុះស្វាយមីងរបស់អ៊ុំនឹងមានឈ្មោះអីគេដែរអ៊ុំ?

ខ៖  ប៉ាវានឹងឈ្មោះតាហុក

ក៖  ចុះអ៊ុំមានចងចាំថ្ងៃដែរអ៊ុំរៀបអាពាហ៍ពិពាហ៍ជាអ៊ុំប្រុសនៅថ្ងៃខែឆ្នាំណាដែរទេអ៊ុំ?

ខ៖  នៅឆ្នាំ1982

ក៖  ឆ្នាំ1982ណាអ៊ុំ?

ខ៖  ដឹងតែឆ្នាំ1982ប៉ុន្តែមិនដឹងថានៅថ្ងៃណាទេភ្លេចបាត់ហើយនឹង
កាលពីជំនាន់ណុងគ្មាននរណា ចងលុយទេ

ក៖  ចុះអ៊ុំប្រុសមានផ្តាប់ជាបណ្ណាការអីទៅអ៊ុំអត់?

ខ៖
ជំនាន់ណុងគ្មាននរណាចងលុយទេគេជូនគោលក្ខណះថាជួយគ្នាទៅវិញទៅមកនឹងហាស

ក៖  អូ៎!បាទអ៊ុំ?

ខ៖  មានគោខ្លះទៅបងប្អូនគេអោយគោ លក្ខណះថាគេចងដៃគោ ចងដៃជ្រូក ចងដៃអង្ករ
មាន់កាលណុង ក្នុងយើងការមួយនឹងហាសស៊ី5យប់5ថ្ងៃមិនទាន់អស់ផងនឹង
ចុះបើសុទ្ធតែគោហើយនឹងមាន់ពេញផ្ទះ ទាំងអស់នឹងហាស

ក៖  បាទអ៊ុំបាទ?

ខ៖  នឹងហើយជំនាន់ណុងគេបង្អែមគេជំឡូងឈឹងហើយនឹងហាស

ក៖  បាទចុះម៉េចបានតាស្រលាញ់អ៊ុំដែរអ៊ុំពេលណុងអ៊ុំមានដឹងអត់?

ខ៖  ខ្ញុំអត់ដឹងទេកាលពីជំនាន់ណុងខ្ញុំដើរលេងអត់ដែរចូលផ្ទះទេទៅលេងភ្លេងហាស

ក៖  បាទអ៊ុំចឹងហោស?

ខ៖  លេងភ្លេង អកកេះ អាយៃឆ្លងឆ្លើយល្ខោននឹងដើរលេងមិនដែរបានចូលផ្ទះទេនឹង

ក៖  ចុះអ៊ុំមានបានរៀនទេអ៊ុំ?

ខ៖
រៀនៗនឹងអូនអើយគ្មានបានរៀនអីទេចុះកាលណុងនៅរួកដើរលេងពេកគ្មានបានរៀនទេ
បានតែសៀវភៅកុមារដ្ឋានគេនឹងបានសៀវភៅរបខ្លាឃ្មុំហាស
បានអាសៀវភៅកុមារដ្ឋានគេនឹងកាលរៀន នៅថ្នាក់ទីមួយហាស
ដល់ពេលឡើងថ្នាក់ទី2នឹងគ្មានបានរៀនទេចុះបើងងុយដេកចង់ស្លាប់ហើយនឹង
គ្នាខ្ញុំនឹងសុទ្ធតែអ្នកល្ងង់ទាំងអស់ សុទ្ធតែអ្នកអត់ចេះអក្សរទាំងអស់នឹង

ក៖ ប៉ុន្តែអ៊ុំបានរៀនថ្នាក់ទីប៉ុន្មានដែរអ៊ុំមិនបានរៀនណាហីអ៊ុំ?

ខ៖ បានតើ បានថាមើលរួចបានសរសេរ

ក៖ ប៉ុន្តែអ៊ុំរៀនបានថ្នាក់ទីប៉ុន្មានដែរអ៊ុំ?

ខ៖ កាលពីជំនាន់ណុងរៀនបានថ្នាក់ទី3នឹង

ក៖ រៀនបានថ្នាក់ទី3ហោសអ៊ុំ?

ខ៖ មិនមែនដូចយើងនៅចំនាន់នេះទេណាស់ថ្នាក់ទី3

ក៖ ចុះកាលពីអ៊ុំរៀននឹងអ៊ុំរៀននៅណាដែរអ៊ុំ?

ខ៖ ខ្ញុំរៀននៅត្រើយស្លានឹង

ក៖ រៀននៅត្រើយស្លាហោសអ៊ុំ?

ខ៖ ចាំ!រៀននៅត្រើយស្លានឹង

ក៖ ចុះអ៊ុំមានមិត្តភក្តិស្និទ្ធស្នាលទេអ៊ុំ?

ខ៖ អត់មានជាមិត្តភក្តិអត់រាប់អានគ្នាទេខ្ញុំមិនយកទេ

ក៖ អ៎ូ!បាទអ៊ុំបាទ?

ខ៖ ខ្ញុំចូលចិត្តដើរលេងតែម្នាក់ឯងៗនឹង

ក៖ ចុះអ៊ុំមានចេះភាសាអីក្រៅពីភាសាខ្មែរទេអ៊ុំ?

ខ៖ ចាំ!ថាម៉េច?

កៈ ចង់និយាយថាអ៊ុំមានចេះភាសាអីក្រៅពីភាសាខ្មែរទេ?

ខៈ អត់ទេចេះតែខ្មែរយើងនឹង

កៈ
អ៊ូ!បាទអ៊ុំចុះអ៊ុំគិតថាអ៊ុំធ្លាប់ធ្វើការងារអីគេខ្លះដែរអ៊ុំតាំងពីក្មេងរហូតមកដល់ពេលនេះហាស
?

ខៈ តាំងបីក្មេងមកហោសចូលចិត្តធ្វើការអីជាងគេហោស?

កៈ អត់ទេអ៊ុំមានធ្វើអីគេខ្លះដែរអ៊ុំ?

ខៈ ខ្ញុំមានលក់តែតវ៉ាន់ចាប់ហ៊្វយនឹង

កៈ អ៊ូ!ចឹងអ៊ុំមានលក់តែតវ៉ាន់ចាប់ហ៊្វយទេណាអ៊ុំ?

ខៈ ពីមុនដំបុងបង្អស់នឹងខ្ញុំលក់បន្លែ
បានក្រោយមកខ្ញុំលក់តវ៉ាន់ចាប់ហ៊្វយនឹងដល់ពេលដែរគេជឿច្រើន
ពេកនឹងបានឈប់លក់ទៅនឹង

កៈ អ៊ូ!បាទអ៊ុំបាទ?

ខៈ កាលពីប៉ាវាឈឺនេះប៉ាវាឈឺមួយឆ្នាំជាងហើយនឹងហាស
វាអត់ទើបតែមួយឆ្នាំជាងនឹងតែម្តងហាស អូនវាអស់ពីខ្លួននឹងតែម្តងនឹង

កៈ ចុះអ៊ុំគិតថាអ៊ុំធ្លាប់ធ្វើស្រែចំការអត់អ៊ុំ?

ខៈ ខ្ញុំហោស?

កៈ បាទអ៊ុំ

ខៈ កាលពីនៅត្រើយស្លាធ្វើ នៅត្រើយស្លានឹងប្តីរបស់ខ្ញុំនឹងធ្វើតែខ្ញុំមិនដែរធ្វើទេ

កៈ ចឹងមានន័យថាអ៊ុំធ្លាប់លក់ដូរដែរ?

ខៈ ចា៎!ធ្លាប់លក់ដែរនឹង

កៈ ចុះអ៊ុំធ្លាប់ចិញ្ចឹមសត្វអីទេអ៊ុំលក្ខណៈថាដូចជាមាន់ ទា ជ្រូក គោ ក្របីអីនឹងហាស?

ខ៖ ចិញ្ចឹមមានតែនឹងកាលពីជំនាន់ណុងមានដែរមាន់ចិញ្ចឹមតែមាន់ទេ

ក៖ អ៊ូ!មានចិញ្ចឹមច្រើនហោសអ៊ុំ?

ខ៖ មាន់នឹងមានមេ6ក្បាល

ក៖
អ៊ូ!បាទអ៊ុំចុះអ៊ុំគិតថាជីវិតរបស់អ៊ុំមានការផ្លាស់ប្តូរអីគេខ្លះដែរអ៊ុំតាំងពីក្មេងរហូតមកដល់ពេលនេះ ចឹងហាសអ៊ុំ?

ខ៖ អត់មានឃើញផ្លាស់ប្តូរអីផងនឹង

ក៖ ធម្មតាហោសអ៊ុំ?

ខ៖ ចា៎!ធម្មតានឹង

ក៖ ចុះអ៊ុំគិតថាល្បែងប្រជាប្រិយ៍អីដែរអ៊ុំគិតថាអ៊ុំចូលចិត្តលេងតាំងពីក្មេងហាសអ៊ុំ មានចោលឈូង ទាញព្រាត លាក់កន្សែង មានស្តេចចង់ រឺមួយក៏ដណ្តើមស្លឹកឈើអីចឹងហាស?

ខ៖ ចូលចិត្តរាំរបាំ

ក៖ ចូលចិត្តរាំហោសអ៊ុំ?

ខ៖ ចា៎!នឹងហើយ

ក៖ ចុះអ៊ុំចូលចិត្តពិសារម្ហូបអីគេដែរអ៊ុំ?

ខ៖ ខ្ញុំហោស?

ក៖ បាទអ៊ុំបាទ

ខ៖ មានអីហូបណុង

ក៖ ចុះដូចជាសំលម្ជូរ ការីដែរធ្វើអោយអ៊ុំចូលចិត្តតែម្តងហាស?

ខ៖ ខ្ញុំចូលចិត្តស្លចាប់ឆាយ

ក៖ អ៊ូ!ចូលចិត្តចាប់ឆាយហោសអ៊ុំ ចុះអ៊ុំចេះច្រៀងអត់អ៊ុំ?

ខ៖  ទៅលែងរួចហើយនឹង

ក៖  ចុះអ៊ុំមានចូលចិត្តស្តាប់បទចំរៀងអត់អ៊ុំ?

ខ៖  ឥឡូវនឹងអត់មានទេអូនធុញហើយនឹង

ក៖
អូ៎!បាទចុះអ៊ុំគិតថាមាននរណាម្នាក់នៅក្នុងក្រុមគ្រួសាររបស់អ៊ុំចេះលេងឧបករណ៍ភ្លេងទេអ៊ុំ
?

ខ៖  អត់មានទេអូន

ក៖  ចឹងអត់មានទេហោសអ៊ុំ ចុះអ៊ុំគិតថាផ្ទះរបស់អ៊ុំនឹងមានលក្ខណះបែបណាដែរអ៊ុំ?

ខ៖  សាមញ្ញធម្មតានឹង

ក៖  អូ៎!ចឹងធម្មតាទេហោសអ៊ុំ?

ខ៖  ធម្មតានឹងឯង

ក៖  ចឹងធម្មតាទេ ចុះផ្ទះរបស់អ៊ុំនឹងនរណាគេជាអ្នកធ្វើដែរអ៊ុំ
ដូចជាអ៊ុំជួលគេរឺមួយក៏អ៊ុំធ្វើខ្លួនឯងដែរ?

ខ៖  ផ្ទះនឹងបងថ្លៃខ្ញុំធ្វើអោយហើយជញ្ជាំងនឹងប្តីរបស់ខ្ញុំនឹងកូនរបស់ខ្ញុំទេ

ក៖  អូ៎!បាទអ៊ុំ?

ខ៖  បងថ្លៃខ្ញុំធ្វើហើយស្លាប់តែម្តងនឹង

ក៖  ចុះអ៊ុំគិតថាជំនាញអីគេដែរអ៊ុំគិតថាអ៊ុំចេះស្ទាត់ជំនាញដែរអ៊ុំ?

ខ៖  ខ្ញុំជំនាញខាងលក់ដូរនឹងហើយ

ក៖  អូ៎!លក់ដូរហោសអ៊ុំចឹង?

ខ៖  ដល់ពេលឥឡូវនឹងវាអត់មានដើមរកស៊ីហើយនឹង

ក៖  ចុះម្តាយឪពុករបស់ពួកគាត់មានធ្លាប់បង្រៀនពីជំនាញអីទៅអ៊ុំដែរទេ
លក្ខណះថាវេញវល្លិ៍ ធ្វើស្ករត្នោត ធ្វើផ្តៅ ធ្វើកន្ទេលអញ្ចូត?

ខ៖

គាត់គ្មានបានធ្វើអីទាំងអស់ពេលដែរយើងកើតមកគ្មានបានអីបើដល់ជំនាន់ពលពតហើយនឹង

ក៖

ចុះអ៊ុំគិតថាពេលណាដែរអ៊ុំគិតថាជាពេលដែរសប្បាយជាងគេនៅក្នុងឆាកជីវិតរបស់អ៊ុំដែរ?

ខ៖ នៅក្នុងឆាកជីវិតរបស់ខ្ញុំដែរសប្បាយជាងគេហោស?

ក៖ បាទអ៊ុំបាទ?

ខ៖ គឺថាដើរលឹងនឹងហើយ

ក៖ អូ៎!ដើរលេងហោសអ៊ុំហោស?

ខ៖ ចា៎!រាល់ថ្ងៃនឹងបន់អោយគេថាអូទៅលេងកំពត ទៅកំពង់សោមនឹងដឹងតែតៅហើយនឹង

ក៖ ដឹងតែទៅហើយណាអ៊ុំ?

ខ៖ ទៅហើយអោយតែនរណាហៅទៅហើយនឹង

ក៖ ចុះអ៊ុំគិតថាកាលពីនៅក្មេងហាស

អ៊ុំគិតថាពេលដែរធំឡើងនឹងអ៊ុំមានក្ដីស្រម៉ៃថាពេលដែរធំឡើងនឹង អ៊ុំចង់ធ្វើអីទេ?

ខ៖ កាលពីក្មេងនឹងខ្ញុំគ្មានស្រម៉ៃទេ

ក៖ ដូចថាជាលក្ខណៈគ្រូបង្រៀន គ្រូពេទ្យអីចឹង?

ខ៖ អត់អូន អត់មានស្រម៉ៃតែម្ដងនឹង

ក៖

ចុះអ៊ុំគិតថាបើសិនជាចង់អោយអ៊ុំផ្ដែផ្ដាំទៅកូនចៅជំនាន់ក្រោយៗនឹងតើអ៊ុំចង់ផ្ដែផ្ដាំអីទៅពួកគាត់ដែរ នឹងអ៊ុំ?

ខ៖ ខ្ញុំផ្ដែផ្ដាំទៅក្មេងជំនាន់ក្រោយហាស

ក៖ បាទអ៊ុំបាទ?

ខ៖ ខ្ញុំចង់ផ្ដែផ្ដាំអោយកូនរបស់ខ្ញុំនឹងក្មេងជំនាន់ក្រោយនឹងកុំអោយមានម៉ាជក់នឹង
កុំអោយវាជក់ម៉ាហាស

ក៖  បាទអ៊ុំ?

ខ៖  នឹងហើយបើជក់ម៉ាខូចសុខភាព វាមិនមានសេរីស្សួរស្តីទេ

ក៖  បាទអ៊ុំត្រូវហើយ?

ខ៖  វាធ្វើអោយកំលាំងចុះខ្សោយ យើងខំរកស៊ីទៅកំអោយជក់ កុំអោយអីនឹង

ក៖  មានអីផ្សេងពីនឹងទៀតអត់អ៊ុំ?

ខ៖  ហើយខ្ញុំជូនពរអោយកូនរបស់ខ្ញុំនឹងម្នាក់ៗអាចរកស៊ីមានបាន

ក៖  បាទអ៊ុំបាទចឹងខ្ញុំអរគុណអ៊ុំដែរបានអោយខ្ញុំបានស្គាល់ពីប្រវត្តិរបស់អ៊ុំ
បាទអរគុណច្រើនអ៊ុំ៕៕៕